# ឈ្នះលោកិយ ហើយបានសេចក្ដីសម្រាក

ដោយ ប្រធាន រ័សុល អិម ណិលសុន
ប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

## ដោយសារ ព្រះយេស៊ូវគ្រីស្ទ បានឈ្នះលោកិយដ៏ធ្លាក់នេះ

ហើយដោយសារទ្រង់បានធួននឹងអំពើបាបយើងម្នាក់ៗ នោះយើងក៏អាចឈ្នះពិភពលោកដែលមានអំពើបាបដ៏ដោតដាំ ដែលអត្មានិយម និងគួរឲ្យនឿយហត់នេះផងដែរ ។



ពេលបងប្អូនប្រែចិត្តដ៏ពិត ហើយស្វែងរកជំនួយពីទ្រង់ នោះបងប្អូនអាចយកឈ្នះលើពិភពលោកដ៏គ្រោះថ្នាក់បច្ចុប្បន្ននេះ ហើយរកឃើញ *សេចក្ដីសម្រាក* ដ៏ពិតប្រាកដ ។

## តើការឈ្នះលោកិយមានន័យដូចម្ដេច ?

វាមានន័យថា ៖

- ការយកឈ្នះលើការល្បួង ដែលនាំឲ្យខ្វល់ខ្វាយច្រើនចំពោះរបស់ផងលោកិយជាងការណ៍ទាំងឡាយនៃព្រះនោះ ។

- ការទុកចិត្តលើគោលលទ្ធិនៃព្រះគ្រីស្ទជាងលើទស្សនៈរបស់មនុស្ស ។

- ការអររីករាយនៅក្នុងសេចក្ដីពិតទប់ទល់ការបោកបញ្ឆោត ហើយប្រែជា « អ្នកដើរតាមព្រះគ្រីស្ទដោយរាបសា » ។

- ការជ្រើសរើសចៀសវាងពីអ្វីដែលនាំឲ្យព្រះវិញ្ញាណចាកចេញ និងការមានឆន្ទៈ « បោះបង់ចោល » អំពើបាបដែលយើងចូលចិត្ត ។

- ការស្រឡាញ់ព្រះ និងព្រះរាជបុត្រាសំណព្វទ្រង់ចម្រើនខ្លាំងឡើងលើសអស់ទាំងការស្រឡាញ់នរណាម្នាក់ ឬអ្វីផ្សេងៗទៀត ។


## តើយើងឈ្នះលោកិយដោយរបៀបណា ?



ស្វែងរក និងធ្វើតាមការបំផុសគំនិតមកពីព្រះវិញ្ញាណ ។



ប្រែចិត្តជាប្រចាំថ្ងៃ ហើយរក្សាសេចក្ដីសញ្ញាទាំងឡាយដែលនាំឲ្យយើងមានអំណាច ។



ចូរបន្តនៅលើផ្លូវនៃសេចក្ដីសញ្ញា ។



ព្រះអង្គសង្គ្រោះ *លើក យើង* ឡើងផុតពីឥទ្ធិពលនៃពិភពលោកដ៏ធ្លាក់នេះ ដោយប្រទានពរដល់យើងឲ្យមានសេចក្ដីសប្បុរស ភាពរាបសា ចិត្តល្អ ចេះលត់ដំខ្លួន មានភាពសុខសាន្ត និង *សេចក្ដីសម្រាក* ។

ដោយសារព្រះយេស៊ូវបានឈ្នះលោកិយនេះ នោះបងប្អូនក៏អាចឈ្នះលោកិយនេះបានផងដែរ ។

*ដកស្រង់ចេញពី សុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០២២ ។*